# ក្រមសីលធម៌ចៅក្រម

**បុព្វកថា**

ចៅក្រមនៃអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា៖

**បានឃើញ**កិច្ចព្រមព្រៀងរវាងអង្គការសហប្រជាជាតិ និងរាជរដ្ឋាភិបាលកម្ពុជាស្តីពីការកាត់ក្តីក្រោមច្បាប់កម្ពុជា ចំពោះឧក្រិដ្ឋកម្មទាំងឡាយ ដែលបានប្រព្រឹត្តិឡើងក្នុងអំឡុងរបបកម្ពុជាប្រជាធិបតេយ្យ ដែលបានចុះហត្ថលេខាកាលពីថ្ងៃទី៦ ខែមិថុនា ឆ្នាំ២០០៣។

**បានឃើញ**ច្បាប់ និង ខ្លឹមសារវិសោធនកម្ម ច្បាប់ស្តីពីការបង្កើតអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ដែលបានប្រកាសឱ្យប្រើជាផ្លូវការកាលពីថ្ងៃទី២៧ ខែតុលា ឆ្នាំ២០០៤។

**បានឃើញ**ក្រមសីលធម៌ចៅក្រម ដែលបានអនុម័តដោយឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រមកាលពីថ្ងៃទី០៥ ខែកុម្ភៈ ឆ្នាំ២០០៧។

**បានគិតគូរ**ដល់គោលការណ៍ជាមូលដ្ឋានរបស់អង្គការសហប្រជាជាតិស្តីពីឯករាជ្យភាពរបស់តុលាការ ឆ្នាំ ១៩៨៥។

**បានយល់ដឹង**ពីចរិតលក្ខណៈកូនកាត់នៃអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា និងភាពចាំបាច់ត្រូវអនុម័តនូវក្រមសីលធម៌ ដែលចៅក្រមជាតិ និងអន្តរជាតិត្រូវអនុវត្តតាម និង ដោយបញ្ចូលនូវនិយាមជាតិ និងអន្តរជាតិ។

**បានព្រមព្រៀងគ្នា**ដូចខាងក្រោម៖

**មាត្រា ១**

**គោលការណ៍ឯករាជ្យភាពរបស់តុលាការ**

១. ចៅក្រមត្រូវរក្សានូវឯករាជ្យភាពនៃការិយាល័យរបស់ខ្លួន និងសិទ្ធិអំណាចរបស់ខ្លួនក្នុងអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា (ហៅកាត់ថា អ.វ.ត.ក) ហើយត្រូវប្រតិបត្តិតាមសិទ្ធិអំណាច និងឯករាជ្យភាពក្នុងការបំពេញតួនាទីរបស់ខ្លួន។

២. ចៅក្រមមិនត្រូវចូលរួមក្នុងសកម្មភាពណាមួយ ដែលទំនងជាជ្រៀតជ្រែកចូលក្នុងការបំពេញមុខនាទីរបស់ខ្លួន ឬអាចប៉ះពាល់ដល់ជំនឿទុកចិត្តលើឯករាជ្យភាពរបស់ខ្លួន។

## មាត្រា ២

## គោលការណ៍អនាគតិ

១. ចៅក្រមត្រូវរក្សានូវភាពមិនលំអៀង និង ត្រូវធានាពីការបង្ហាញពីភាពមិនលំអៀងនោះក្នុងការបំពេញមុខនាទីរបស់ខ្លួន។

២. ចៅក្រមត្រូវចៀសវាងនូវរាល់ជម្លោះផលប្រយោជន៍ ឬ ស្ថិតក្នុងស្ថានភាពណាមួយដែលគេអាចយល់ឃើញថាមានជម្លោះផលប្រយោជន៍កើតឡើង។

## មាត្រា ៣

## គោលការណ៍សុចរិតភាព

(វិសោធនកម្មថ្ងៃទី ០៥ ខែកញ្ញា ឆ្នាំ ២០០៨)

១. ចៅក្រមត្រូវប្រតិបត្តិខ្លួនដោយភាពថ្លៃថ្នូរ ដោយសីលធម៌ និង ដោយសេចក្តីសុចរិតទៀងត្រង់តាមការិយាល័យរបស់ខ្លួន ដើម្បីលើកកម្ពស់ជំនឿទុកចិត្តពីសាធារណជនលើតុលាការ។

២. ចៅក្រមមិនត្រូវទទួលយក ឬ សំណើផ្តល់ ឬ ផ្តល់នូវអំណោយ (កាដូ) ផលប្រយោជន៍ បុព្វសិទ្ធិ ឬ រង្វាន់ទោះដោយផ្ទាល់ក្តី ឬ ដោយប្រយោលក្តី ដែលគេអាចយល់បានថា កំពុងតែមានចេតនាជះឥទ្ធិពលលើការបំពេញមុខនាទី ឬ ឯករាជ្យភាពនៃការងាររបស់ខ្លួន។

## មាត្រា ៤

## គោលការណ៍ភាពសម្ងាត់

ចៅក្រមត្រូវគោរពនូវសារសំខាន់នៃការរក្សាភាពសម្ងាត់ ចំពោះពត៍មានដែលទទួលបានក្នុងការបំពេញមុខនាទីរបស់ខ្លួន និង ភាពសម្ងាត់នៃការពិភាក្សាសម្រេច។

### មាត្រា ៥

### គោលការណ៍វីរយភាព

១. ចៅក្រមត្រូវបំពេញតួនាទីភារកិច្ចរបស់ខ្លួនដោយសេចក្ដីសង្វាតព្យាយាម និងប្រើសមត្ថភាពវិជ្ជាជីវៈរបស់ខ្លួនដើម្បីបំពេញភារកិច្ចទាំងនោះ។

២. ចៅក្រមត្រូវចាត់វិធានការសមស្របដើម្បីរក្សា និងលើកកម្ពស់ចំណេះដឹង ជំនាញ និងសមត្ថភាពផ្ទាល់ខ្លួន ដែលចាំបាច់សម្រាប់បំពេញតួនាទីរបស់ខ្លួន។

៣. ចៅក្រមត្រូវបំពេញគ្រប់តួនាទីភារកិច្ចតុលាការឱ្យបានឆាប់រហ័ស និងត្រឹមត្រូវ។

៤. ចៅក្រមត្រូវចេញសេចក្ដីសម្រេចរបស់ខ្លួន ដោយគ្មានការពន្យាពេល ដែលមិនសមរម្យ។

### មាត្រា ៦

### គោលការណ៍អាកប្បកិរិយាក្នុងដំណើរការក្ដី

១. នៅក្នុងកិច្ចដឹកនាំដំណើរការក្ដី ចៅក្រមត្រូវរក្សានូវសណ្ដាប់ធ្នាប់ របៀបរៀបរយ រៀបចំអាកប្បកិរិយាគួរជាទីគោរព រក្សាភាពអត់ធ្មត់ និងការគួរសមចំពោះអ្នកចូលរួមទាំងអស់ ក៏ដូចជាសាធារណជនដែលមានវត្តមាន ហើយត្រូវតម្រូវឱ្យអ្នកទាំងនោះអនុវត្តដូចគ្នាដែរ។

២. ចៅក្រមត្រូវយកចិត្តទុកដាក់ក្នុងការគ្រប់គ្រងលើឥរិយាបទក្នុងការសួរសំណួរលើសាក្សី ឬជនរងគ្រោះ និងផ្ដល់ការយកចិត្តទុកដាក់ជាពិសេសលើសិទ្ធិរបស់អ្នកចូលរួមក្នុងដំណើរការក្ដីក្នុងការទទួលបានការការពារ និងអត្ថប្រយោជន៍តាមផ្លូវច្បាប់។

៣. ចៅក្រមត្រូវចៀសវាងនូវការដឹកនាំ ឬការជូនយោបល់ណាមួយដែលមានភាពរើសអើងពូជសាសន៍ភេទ ឬបន្ទាបបន្ថោក។ បើអាចធ្វើទៅបាន ចៅក្រមត្រូវធ្វើយ៉ាងណាឱ្យអ្នកចូលរួមក្នុងដំណើរការក្ដីចៀសវាងពីការផ្ដល់នូវយោបល់ ឬប្រព្រឹត្តិអំពើបែបនោះ។

### មាត្រា ៧

### គោលការណ៍សម្ដែងមតិជាសាធារណៈ និងទំនាក់ទំនងជាមួយសាធារណៈ

១. ចៅក្រមត្រូវអនុវត្តសិទ្ធិក្នុងការបញ្ចេញមតិ និងចូលរួមក្នុងកិច្ចការសាធារណៈណាដែលសមស្របជាមួយនឹងមុខនាទីនៃការិយាល័យរបស់ខ្លួន ហើយដែលមិនជះឥទ្ធិពល ឬទំនងជាអាចជះឥទ្ធិពលដល់ឯករាជ្យភាព និងភាពមិនលំអៀងរបស់តុលាការ។

២. ទោះបីចៅក្រមអាចចូលរួមដោយសេរីក្នុងការពិភាក្សាវែកញែកជាសាធារណៈលើបញ្ហាទាំងឡាយទាក់ទងនឹងបញ្ហាច្បាប់ តុលាការ ឬរដ្ឋបាលតុលាការ ចៅក្រមមិនត្រូវជូនយោបល់ណាមួយទាក់ទងនឹងសំណុំរឿងដែលរង់ចាំការកាត់សេចក្តី ហើយចៅក្រមត្រូវចៀសវាងការបញ្ចេញទស្សនៈទាំងឡាយណាដែលអាចធ្វើឱ្យប៉ះពាល់ជាអវិជ្ជមានដល់កេរ្តិ៍ឈ្មោះ និងសុចរិតភាពរបស់អ.វ.ត.ក។

**មាត្រា ៨**

**គោលការណ៍សកម្មភាពក្រៅកិច្ចការតុលាការ**

១. ចៅក្រមមិនត្រូវចូលរួមក្នុងសកម្មភាពក្រៅកិច្ចការតុលាការណាមួយដែលមិនត្រូវជាមួយនឹងមុខងារតុលាការរបស់ខ្លួន ឬការប្រព្រឹត្តទៅប្រកបដោយប្រសិទ្ធភាព និងទាន់ពេលវេលារបស់អ.វ.ត.ក ឬដែលអាចជះឥទ្ធិពល ឬទំនងជាអាចជះឥទ្ធិពលដល់ឯករាជ្យភាព និងភាពមិនលំអៀងរបស់ខ្លួន។

២. ចៅក្រមមិនត្រូវកាន់តួនាទីនយោបាយឡើយ។

**មាត្រា ៩**

**ការអនុវត្តក្រម**

១. គោលការណ៍ទាំងឡាយដែលមានចែងក្នុងក្រមនេះត្រូវចាត់ទុកជាសេចក្តីណែនាំស្តីពីបទដ្ឋានសីលធម៌ជាសារវ័ន្ត ដែលចៅក្រមត្រូវប្រកាន់ខ្ជាប់ក្នុងការបំពេញតួនាទីនិងភារកិច្ចរបស់ខ្លួន។

២. មិនមានអ្វីមួយក្នុងខ្លឹមសារនៃក្រមនេះដែលសំដៅកំណត់ ឬដាក់កំហិតតាមមធ្យោបាយណាមួយទៅលើឯករាជ្យភាពរបស់ចៅក្រមឡើយ។

អនុម័តដោយកិច្ចប្រជុំពេញអង្គ នៅថ្ងៃទី ០១ ខែកុម្ភៈ ឆ្នាំ ២០០៨ និង វិសោធនកម្មដោយកិច្ចប្រជុំពេញអង្គ នាថ្ងៃទី ០៥ ខែកញ្ញា ឆ្នាំ ២០០៨ ។